# ការពិនិត្យឡើងវិញនូវអនុស្សរណៈនៃការយោគយល់គ្នា
# ស្តីពី
# ក្រុមការងារប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ

អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីក្រុមការងារប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០៤ ដែលជាមូលដ្ឋានគ្រឹះនៃកិច្ចសហការគ្នារវាងបណ្តារដ្ឋាភិបាលនៅមហាអនុតំបន់មេគង្គ ក៏ដូចជាបណ្តាលអ្នកពាក់ព័ន្ធផ្សេងៗទៀតក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ អនុស្សរណៈនេះគឺជាកិច្ចព្រមព្រៀងដ៏ទូលំទូលាយដោយយោងទៅលើបទដ្ឋានអន្តរជាតិជុំវិញក្របខ័ណ្ឌយុទ្ធសាស្ត្រ 4P ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងការតាមដាន និងវាយតម្លៃដែល មានដូចជា៖

**១.គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ**

**២.ការបង្ការទប់ស្កាត់**

**៣.ការការពារ**

**៤.ការផ្តន្ទាទោស**

កាលពីកិច្ចប្រជុំឧត្តមមន្ត្រីឧមមីតលើកទី១៣ ក្នុងឆ្នាំ២០១៩ កិច្ចពិភាក្សាថ្នាក់តំបន់រវាងតំណាងរដ្ឋាភិបាលបានស្នើឱ្យមានការពិនិត្យមើលលទ្ធភាពនៃការពិនិត្យឡើងវិញនូវអនុស្សរណៈនេះ ខណៈមានទស្សនៈផ្សេងៗបានលើកឡើងថាតើការពិនិត្យឡើងវិញនេះជាការចាំបាច់ដែលឬទេ ទោះជាយ៉ាងណាក៏ដោយ សំណើនេះត្រូវបានយល់ព្រមដោយអង្គប្រជុំ។

ក្នុងនោះក៏មានការឯកភាពគ្នាចំពោះនីតិវិធីនៅក្នុងការផ្តល់យោបល់ និងការពិនិត្យ ត្រូវតែមានការផ្តល់ព័ត៌មានជាមួយលេខាធិការដ្ឋាន។

- បានយល់ព្រម ចំពោះការផ្តល់មតិនឹងត្រូវធ្វើឡើងនៅក្នុងក្នុងប្រជុំឧត្តមមន្ត្រីលើកទី១៤ និងវិសោធនកម្ម នឹងធ្វើនៅក្នុងកិច្ចប្រជុំឧត្តមមន្ត្រី។
- ប្រសិនជាមានការឯកភាពចំពោះការធ្វើវិសោធនកម្ម នោះសេចក្តីពិនិត្យឡើងវិញនៃអនុស្សរណៈនៃការយោគយល់នេះនឹងត្រូវបានបញ្ចប់សម្រាប់ការចុះហត្ថលេខានៅក្នុង**ថ្នាក់រដ្ឋមន្ត្រី ២០២១**។

- ជាផ្លូវការនៅក្នុងដំណើរការសើរើតម្រូវឱ្យមានការស្នើសុំពីរដ្ឋាភិបាលចំនួន៤ ខណៈដែលការពិនិត្យនេះត្រូវបានស្នើសុំជារួម យើងនឹងឯកភាព និងលទ្ធភាពថាតើសំណើនេះអាចទទួលបានការឯកភាពនៅកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីលើកទី១៤ បានដែលឬទេ។
- រាល់ការកែប្រែនានា ចាំបាច់ត្រូវមានការយល់ព្រមជាឯកច្ឆន្ទពីសំណាក់រដ្ឋាភិបាលទាំង ៦ ហើយការយល់ព្រមពីរដ្ឋាភិបាលនីមួយៗនឹងត្រូវផ្ញើទៅលេខាធិការដ្ឋានជាលាយលក្ខណ៍អក្សរ។